**ស្ថានទូតអូស្ត្រាលី**
**ប្រចាំទីក្រុងភ្នំពេញ**

# សេចក្តីប្រកាសពត៌មាន

## លោក នាយករដ្ឋមន្ត្រីអូស្ត្រាលី ខេវិន រ៉ាដ នឹងចូលរួមប្រជុំនៅទីក្រុងខូផិនហាហ្គែន ស្តីពី ការប្រែប្រួលអាកាសធាតុ

ថ្ងៃនេះ លោក **ឡាស រ៉ាសមូសេន** (LarsRasmussen) នាយករដ្ឋមន្ត្រីនៃប្រទេសដាណោម៉ាក បានអញ្ជើញនាយករដ្ឋមន្ត្រីអូស្ត្រាលី និងប្រមុខរដ្ឋដទៃទៀតដើម្បីចូលរួមសន្និសិទអង្គការសហប្រជាជាតិ ស្តីពី ការប្រែប្រួលអាកាសធាតុ នៅទីក្រុងខូផិនហាហ្គែន (Copenhagen) នៅថ្ងៃទី ១៧-១៨ ខែធ្នូ ឆ្នាំ២០០៩ ។

លោកនាយករដ្ឋមន្ត្រី **ខេវិន រ៉ាដ** បានប្រកាសនៅថ្ងៃនេះថា លោកនឹងអញ្ជើញចូលរួមប្រជុំជាមួយមេដឹកនាំនៃប្រទេសដទៃទៀតនៅសន្និសិទទីក្រុងខូផិនហាហ្គែន ។

កិច្ចប្រជុំនៅទីក្រុងខូផិនហាហ្គែន បង្ហាញនូវឱកាសដ៏មានសារៈសំខាន់មួយនៅក្នុងកិច្ចខិតខំប្រឹងប្រែងជាអន្តរជាតិដើម្បីឈានទៅរកកិច្ចព្រមព្រៀងដ៏រឹងមាំមួយ ស្តីពីសកម្មភាពជាសាកលក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុប្រកបដោយប្រសិទ្ធិភាព ។

សំរាប់ពេលបច្ចុប្បន្ន និងទៅអគនាគត វាជាការសំខាន់ដែលថា ប្រទេសជាតិទាំងឡាយធ្វើការជាមួយគ្នាឆ្ពោះទៅរកដំណោះស្រាយជាសាកលមួយដើម្បីទប់ទល់ទៅនឹងការប្រែប្រួលអាកាសធាតុនេះ ។


*ទំនាក់ទំនងសារព័ត៌មាន:*

***Ms Fiona Cochaud, DHOM, 023 213 470***
**Australian Embassy Phnom Penh**

23 October 2009